ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

26-08-25

អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

លេខ ០៦០ អ.ស.ហ.ប្រ.ក

# ប្រកាស
## ស្តីពី
## ការបំពេញបន្ថែមលើប្រកាសស្តីពីកម្រៃសេវានៃការចុះបញ្ជីបរធនបាលកិច្ច ចំពោះសេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកសម្រាប់ប្រអប់សុវត្ថិភាព

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
## និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០២ ចុះថ្ងៃទី២ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីបរធនបាលកិច្ច
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញអនុក្រឹត្យលេខ ៤៧៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣ ស្តីពីបរធនបាលកិច្ចហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី២ ខែសីហា ឆ្នាំ២០១៩ ស្តីពីការចុះបញ្ជីបរធនបាលកិច្ច
- ប្រកាសលេខ ០១០ អ.ស.ហ.ប្រក ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីកម្រៃសេវានៃការចុះបញ្ជីបរធនបាលកិច្ច
- យោងតាមតម្រូវការចាំបាច់របស់និយ័តករបរធនបាលកិច្ច

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះកំណត់អំពីការបំពេញបន្ថែម លើប្រកាសលេខ ០១០ អ.ស.ហ.ប្រក ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីកម្រៃសេវានៃការចុះបញ្ជីបរធនបាលកិច្ច ក្នុងការកំណត់កម្រៃសេវាចុះបញ្ជីបរធនបាលកិច្ចចំពោះសេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកសម្រាប់ប្រអប់សុវត្ថិភាព ដើម្បីបង្កើនប្រសិទ្ធភាពដល់ការចុះបញ្ជីបរធនបាលកិច្ចសេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកសម្រាប់ប្រអប់សុវត្ថិភាព ព្រមទាំងដើម្បីធានាបានគណនេយ្យភាព និងប្រសិទ្ធភាពនៃការប្រមូលកម្រៃសេវានៃការចុះបញ្ជីបរធនបាលកិច្ច ដោយអនុលោមតាមច្បាប់ស្តីពីបរធនបាលកិច្ច និងបទប្បញ្ញត្តិក្នុងវិស័យបរធនបាលកិច្ចជាធរមាន។

**ប្រការ២.-**

ប្រកាសនេះ មានវិសាលភាពអនុវត្ត ចំពោះបរធនបាលកិច្ចសេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកសម្រាប់ប្រអប់សុវត្ថិភាព ដែលត្រូវបានបង្កើត និងចុះបញ្ជី ក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## កម្រៃសេវា

**ប្រការ៣.-**

បុគ្គលដាក់ពាក្យស្នើសុំចុះបញ្ជីបរធនបាលកិច្ចសេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកសម្រាប់ប្រអប់សុវត្ថិភាព ត្រូវបង់ថ្លៃពាក្យស្នើសុំបង្កើត និងចុះបញ្ជីបរធនបាលកិច្ចសេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកសម្រាប់ប្រអប់សុវត្ថិភាព ចំនួន ២០.០០០ (ម្ភៃពាន់) រៀល និងកម្រៃរដ្ឋបាលចំនួន ២០.០០០ (ម្ភៃពាន់) រៀល និងសោហ៊ុយវិញ្ញាបនបត្រចុះបញ្ជីប្រចាំឆ្នាំចំនួន ៦០.០០០ (ហុកសិបពាន់) រៀល ក្នុង ១ (មួយ) ករណី។

**ប្រការ៤.-**

រាល់ការស្នើសុំផ្លាស់ប្តូរបរធនបាល ឬលិខិតបរធនបាលកិច្ចសម្រាប់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកសម្រាប់ប្រអប់សុវត្ថិភាព ឬការផ្លាស់ប្តូរណាមួយពាក់ព័ន្ធនឹងសំណុំលិខិតបរធនបាលកិច្ចសម្រាប់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកសម្រាប់ប្រអប់សុវត្ថិភាព ឬសំណុំលិខិតផ្សេងៗនៃការចុះបញ្ជីបរធនបាលកិច្ចសេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកសម្រាប់ប្រអប់សុវត្ថិភាពត្រូវបង់សោហ៊ុយចំនួន១០០.០០០(មួយរយពាន់)រៀលក្នុង១(មួយ)ករណី។

**ប្រការ៥.-**

វិញ្ញាបនបត្រចុះបញ្ជីបរធនបាលកិច្ចសេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកសម្រាប់ប្រអប់សុវត្ថិភាព ត្រូវមានសុពលភាពទៅតាមរយៈពេលកំណត់នៃបរធនបាលកិច្ច ដូចមានចែងក្នុងលិខិតបរធនបាលកិច្ច។

បុគ្គលដាក់ពាក្យស្នើសុំ ត្រូវដាក់ពាក្យស្នើសុំបន្តសុពលភាពវិញ្ញាបនបត្រចុះបញ្ជីបរធនបាលកិច្ចសេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកសម្រាប់ប្រអប់សុវត្ថិភាពមក **និយ័តករបរធនបាលកិច្ច** (**ន.ប.ធ.**) តាមទម្រង់ និងផ្តល់ឯកសារភ្ជាប់ ដែលកំណត់ដោយ **ន.ប.ធ.** ឱ្យបានយ៉ាងតិច ៣០ (សាមសិប) ថ្ងៃ មុនកាលបរិច្ឆេទវិញ្ញាបនបត្រចុះបញ្ជីបរធនបាលកិច្ចអស់សុពលភាព និងត្រូវបង់សោហ៊ុយបន្តសុពលភាពវិញ្ញាបនបត្រចុះបញ្ជីបរធនបាលកិច្ច ដូចមានចែងក្នុងប្រការ៣ នៃប្រកាសនេះ។

**ប្រការ៦.-**

បុគ្គលដាក់ពាក្យស្នើសុំ ត្រូវកំណត់ឱ្យបានជាក់លាក់នូវប្រភេទបរធន ឬទ្រព្យសម្បត្តិបរធនបាលកិច្ច ដែលមានក្នុងលិខិតបរធនបាលកិច្ច ហើយត្រូវផ្តល់ព័ត៌មានអំពីអត្តសញ្ញាណបរធន ឬទ្រព្យសម្បត្តិបរធនបាលកិច្ច មក **ន.ប.ធ.** ដូចមានក្នុងពាក្យស្នើសុំបង្កើត និងចុះបញ្ជីបរធនបាលកិច្ចសេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកសម្រាប់ប្រអប់សុវត្ថិភាព។ ក្នុងករណីដែលបរធនបាលទាយកមិនមានបំណងបង្ហាញបរធន ឬទ្រព្យសម្បត្តិបរធនបាលកិច្ច បរធនបាលត្រូវមានវិធីសាស្ត្រសមស្របសម្រាប់កំណត់អត្តសញ្ញាណបរធន ឬទ្រព្យសម្បត្តិបរធនបាលកិច្ច។

**ប្រការ៧.-**

បុគ្គលដាក់ពាក្យស្នើសុំ ត្រូវដាក់ពាក្យស្នើសុំបញ្ចប់បរធនបាលកិច្ចសេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកសម្រាប់ប្រអប់សុវត្ថិភាពមក **ន.ប.ធ.** តាមទម្រង់ និងផ្តល់ឯកសារភ្ជាប់ ដែលកំណត់ដោយ **ន.ប.ធ.** ឱ្យបានយ៉ាងតិច ៣០ (សាមសិប) ថ្ងៃ មុនកាលបរិច្ឆេទវិញ្ញាបនបត្រចុះបញ្ជីបរធនបាលកិច្ចអស់សុពលភាព។

## ជំពូកទី៣
## ទណ្ឌកម្ម

**ប្រការ៨.-**

បរធនបាលដែលមិនអនុវត្តតាមកាតព្វកិច្ច និងការទទួលខុសត្រូវក្នុងការបង្កើតនិងចុះបញ្ជីបរធនបាលកិច្ចសេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកសម្រាប់ប្រអប់សុវត្ថិភាព ដូចមានចែងក្នុងប្រកាសនេះ ត្រូវទទួលរងវិធានការរដ្ឋបាលពីមន្ត្រីអធិការកិច្ចបរធនបាលកិច្ច ដូចខាងក្រោម៖

-ការព្រមាន

-ការដឹកនាំកែតម្រង់

-ការដាក់កំហិតលើអាជ្ញាបណ្ណ ឬការអនុញ្ញាត ឬការចុះបញ្ជី

-ការដាក់កំហិតលើការចាត់ចែង និងគ្រប់គ្រងបរធន ឬទ្រព្យសម្បត្តិបរធនបាលកិច្ចចុះបញ្ជី

-ការព្យួរអាជ្ញាបណ្ណ ឬការអនុញ្ញាត ឬការចុះបញ្ជី

-ការព្យួរ ឬបណ្តេញចេញពីមុខតំណែងអភិបាល បុគ្គលិកជាន់ខ្ពស់ និង/ឬបុគ្គលប្រព្រឹត្តល្មើស

-ការដកហូតអាជ្ញាបណ្ណ ឬការអនុញ្ញាត ឬការចុះបញ្ជី។

**ប្រការ៩.-**

ដោយមិនទាន់គិតពីទោសទណ្ឌផ្សេងទៀត បរធនបាលដែលយឺតយ៉ាវឬខកខានក្នុងបង់សោហ៊ុយវិញ្ញាបនបត្រប្រចាំឆ្នាំ ដូចមានចែងក្នុងប្រការ៣ នៃប្រកាសនេះ ត្រូវទទួលរងការផាកពិន័យដោយមន្ត្រីអធិការកិច្ចបរធនបាលកិច្ច ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៦០.០០០.០០០ (ហុកសិបលាន) រៀល។

បរធនបាល ត្រូវទទួលខុសត្រូវលើការបង់ប្រាក់ពិន័យ ដោយមិនត្រូវយកបរធននៃបរធនបាលកិច្ចមកចំណាយជំនួសនោះទេ។

ក្នុងករណីនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែល ត្រូវទទួលការផាកពិន័យជាប្រាក់ដោយមន្ត្រីអធិការកិច្ចបរធនបាលកិច្ច ចំនួនទ្វេឡើងនៃទឹកប្រាក់ផាកពិន័យលើកមុន។

ករណីការប្រព្រឹត្តល្មើសបានបង្កឱ្យមានព្យសនកម្ម ឬបង្កឱ្យខូចប្រយោជន៍ដល់បរធនបាលទាយក អត្ថគាហកៈ ឬភាគីពាក់ព័ន្ធ ឬបុគ្គលប្រព្រឹត្តល្មើសត្រូវផាកពិន័យពីមន្ត្រីអធិការកិច្ចបរធនបាលកិច្ចនៃ **ន.ម.ធ.** ចំនួន ៣ (បី) ដងនៃទំហំទ្រព្យសនកម្មដែលបានបង្កនោះ។

បទប្បញ្ញត្តិនៃជំពូកទោល (បទប្បញ្ញត្តិទូទៅ) នៃមាតិកាទី១ (បទប្បញ្ញត្តិទូទៅ) ជំពូកទោល (ការបង្ខំដល់រូបរាងកាយ) នៃមាតិកាទី៣ (ការបង្ខំដល់រូបរាងកាយ) នៃគន្ថីទី៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវយកមកអនុវត្តក្នុងករណីដែលសេចក្តីសម្រេចអំពីការផាកពិន័យបានចូលជាស្ថាពរ។

**ប្រការ១០.-**

បែបបទ និងនីតិវិធីនៃការចាត់វិធានការរដ្ឋបាល និងការផាកពិន័យដូចមានចែងក្នុងជំពូកនេះ ត្រូវកំណត់ដោយប្រកាសស្តីពីបែបបទ និងនីតិវិធីនៃការដាក់ទណ្ឌកម្មរដ្ឋបាល និងការពិន័យអន្តរការណ៍ក្នុងវិស័យបរធនបាលកិច្ច។

**ប្រការ១១.-**

វិធានការរដ្ឋបាល និងការផាកពិន័យដូចមានចែងក្នុងជំពូកនេះ មិនរារាំងការអនុវត្តច្បាប់ព្រហ្មទណ្ឌជាធរមាន និងដោយមិនទាន់គិតដល់សំណងនៃការខូចខាតផ្សេងទៀត។

## ជំពូកទី៤
## អន្តរប្បញ្ញត្តិ

**ប្រការ១២.-**

បុគ្គលដែលបានដាក់ពាក្យស្នើសុំចុះបញ្ជីបរធនបាលកិច្ចសេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកសម្រាប់ប្រអប់សុវត្ថិភាព តែមិនទាន់បានបង់រួចរាល់នូវកម្រៃសេវានានា ពាក់ព័ន្ធនឹងការចុះបញ្ជីមុនប្រកាសនេះចូលជាធរមាន ត្រូវអនុវត្តការបង់កម្រៃតាមប្រកាសនេះ។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**ប្រការ១៣.-**

**ន.ម.ធ.** អាចចេញគោលការណ៍ណែនាំអនុលោមតាមច្បាប់ស្តីពីបរធនបាលកិច្ច អនុក្រឹត្យស្តីពីការចុះបញ្ជីបរធនបាលកិច្ច និងប្រកាសនេះ ដើម្បីសម្រួលដល់ការយល់ដឹង និងការអនុវត្តតាមលក្ខខណ្ឌនៃប្រកាសនេះ។

**ប្រការ១៤._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៥._**

អគ្គលេខាធិការនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច អគ្គនាយកនៃនិយ័តករ ប្រធានអង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និងបុគ្គលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ចន្ទ ២ កើត ខែភទ្របទ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ សីហា ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់អង្គភាពនិងសមាសភាពក្រុមប្រឹក្សានៃ អ.ស.ហ. "ដើម្បីជូនជ្រាប"
- ដូចប្រការ១៥ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ